# សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ: ..................ស.ខ.ក.ក.

# លិខិតអំពាវនាវ

សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមព្រះអនុញ្ញាត និងអនុញ្ញាត ប្រគេន និងជម្រាបជូន ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ព្រះមេត្តា និងមេត្តាជ្រាបថា ការស្រាវជ្រាវយកឯកសារទាក់ទងនឹងទឹកដីខ្មែរកម្ពុជាក្រោមនៅ Aix-En-Provence ប្រទេសបារាំងបានបញ្ចប់ដោយជោគជ័យ។

ការស្រាវជ្រាវរបស់យើងបានរកឃើញឯកសារសំខាន់ៗ ដែលទាក់ទងនឹងការកាត់ផ្ទេរទឹកដីខ្មែរកម្ពុជាក្រោមរបស់អាណានិគមបារាំង ឱ្យអាណានិគមយួនត្រួតត្រាបន្ត មានដូចជា សន្ធិសញ្ញាបារាំង-យួន, កិច្ចព្រមព្រៀងបារាំង-យួន, កំណត់ហេតុប្រជុំសភាបារាំងក្នុងការផ្ទេរទឹកដីខ្មែរឲ្យយួន, ច្បាប់កាត់ផ្ទេរទឹកដីខ្មែរឲ្យយួន, ការទាមទារទឹកដីខ្មែរកម្ពុជាក្រោមមកវិញរបស់អតីតព្រះមហាក្សត្រខ្មែរ, ការប្រឆាំងជំទាស់ការតវ៉ារបស់រាជរដ្ឋាភិបាលខ្មែរ និងអតីតព្រះមហាក្សត្រខ្មែរជាដើម។ ឯកសារសំខាន់ៗ ដែលយើងរកឃើញមានប្រមាណជាង ៥.០០០ទំព័រ ហើយតម្លៃដែលត្រូវថតចម្លងចេញពីបណ្ណាសារដ្ឋានជាតិបារាំង Aix-En-Provence នោះ ចំនួន ១៦.០០០€ (មួយម៉ឺនប្រាំមួយពាន់អឺរ៉ូ) ជិតពីរម៉ឺនដុល្លារអាមេរិក។

នេះជាជោគជ័យជាប្រវត្តិសាស្ត្រដ៏ធំធេងមិនធ្លាប់មាន ដែលផ្តើមចេញពីការខិតខំតស៊ូរបស់ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ និងយុវជនខ្មែរនៅគ្រប់ទិសទី ដែលបានជួយឧបត្ថម្ភគាំទ្រនិងចូលរួមធ្វើមហាបាតុកម្មយ៉ាងសកម្មកន្លងមក។

ដើម្បីថតចម្លងយកឯកសារដ៏មានសារសំខាន់នេះ មកប្រើប្រាស់ជាប្រយោជន៍ដល់ជាតិខ្មែរយើង សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមលំឱនកាយគោរពអំពាវនាវដល់ព្រះករុណាព្រះតេជគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនជនរួមជាតិទាំងអស់ សូមព្រះមេត្តា និងមេត្តាជួយឧបត្ថម្ភជាថវិកាជាបន្ទាន់ទៅតាមសទ្ធាជ្រះថ្លា ដើម្បីយើងខ្ញុំមានលទ្ធភាពបង់ថ្លៃថតចម្លងចំនួន ១៦.០០០€ ព្រោះគេនឹងថតចម្លងឲ្យយើងនៅពីរសប្តាហ៍ខាងមុខនេះ។ ចំពោះការបកប្រែជាភាសាខ្មែរ ជាភាសាអង់គ្លេស និងការបោះពុម្ព យើងខ្ញុំនឹងជម្រាបជូនខាងក្រោយ។

សហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំទៅលើស្មារតីស្នេហាជាតិរបស់ព្រះករុណាគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ក្នុងការឆ្លើយតបតាមការអំពាវនាវរបស់យើងខ្ញុំទាន់ពេលវេលា ដើម្បីជំរុញបេសកកម្មជាតិឲ្យដល់គោលដៅជាក់ជាមិនខាន។

វិភាគទានរបស់ព្រះករុណាព្រះតេជគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនជនរួមជាតិ ពិតជាបានចូលរួមចំណែកកសាងប្រវត្តិសាស្ត្រ និងបម្រើផលប្រយោជន៍ជាតិខ្មែរដ៏ពិតប្រាកដ។

---

ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦

E-mail: thachsetha13@gmail.com, Website: khmerkromngo.org

សូមប្រគេនពរនិងជូនពរនូវពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម
ប្រធានបណ្ដោះអាសន្នសម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ

ថាច់ សេដ្ឋា

*សូមទាក់ទង:*

*នៅកម្ពុជា:* ០១២ ៩០៨ ៨៨២
០១២ ៨៨០ ៣៨៨
០៧៧ ៣៧៣ ៧៣៦
០១០ ៩១៩៩៩៨

*នៅអឺរ៉ុប:*

| | |
|---|---|
| លោក វ៉ាន់ វណ្ណារិន | ០៦ ៥៨ ៨៨ ៩០ ៦០ |
| ព្រះតេជគុណ អ៊ួង សុខ (បារាំង) | ០៦ ៦៤ ៥៩ ៨៧ ៨៤ |
| លោក ផាយ ភាព (បារាំង) | ០៦ ២០ ៣០ ៨៨ ៣៨ |
| លោក ពេជ្រ សម្បូណ៌ (បារាំង) | ០៦ ២៦ ៣៩ ៩៤ ៦១ |
| លោក ថាច់ សុទ្ធ (បារាំង) | ០៦ ៦០ ៦៤ ៨៣ ៩៥ |
| លោក ទេព មនោរម្យ (បារាំង) | ០៦ ២២ ៨៩ ៦៦ ១២ |
| លោក ហ៊ី ណាន (បែលហ្សិក) | ០០៣២ ៨៣២១ ១៧៧៩ |
| លោក សាង វឺន (ហូល្លង់) | ០០៣១ ៩១៦៦៩ ៣៨៦២ |
| លោក ទឹម សាខន (ស៊ុយអ៊ែត) | ០០៤៦៧ ២២១៤ ៩៧៥៣ |

*នៅទ្វីបអាមេរិកខាងជើង:*

| | |
|---|---|
| លោក គិម សកល | ៩៧៨.៥៩៦.៥១២៦ |
| លោក ថាច់ តាន់តារា | ២៨១.៣៩៩.០១២៤ |
| លោក គិម វុឌ្ឍី | ៨៦៩.៨៩៩.១៩៩១ |
| លោក សឺន ស៊ីណា | ២៦៧.២៩២.៣៦០៨ |
| លោក គិម សូវង្ស | ៦៤៧.៧៨៣.១៥៥១ |

*នៅអូស្ត្រាលី:*

| | |
|---|---|
| ព្រះតេជគុណ ជុំ វណ្ណា | ០៧ ៣៨០៣ ០៨៩៥ |
| លោក ធឿន រតនា | ៦១ ៩២៣ ៣៧៩ ០៩២ |

*នៅនូវហ្សេឡង់:*

| | |
|---|---|
| វត្តខ្មែរក្រោម Auckland, NZ | ០៩២ ២៧៦ ៧៥២ |
| លោក សឺន ច័ន្ទ | ០០៦៤ ៩៩៧០ ៩៩៣០ |
| លោក ថាច់ ខេមរិទ្ធិ | ០០៦៤ ២១៩៥ ៥៣៨៥ |

---